# មូលធនសង្គមក្នុងសហគមន៍នៅតំបន់ទីក្រុង និងជនបទ នៅកម្ពុជា[១]

## សេចក្តីផ្តើម

សង្គមវិទូ James Coleman (1988) និងអ្នកវិទ្យាសាស្ត្រនយោបាយ Robert Putnam (1993) នាពេលថ្មីៗនេះ បានសិក្សា និងផ្សព្វផ្សាយបង្កើនប្រជាប្រិយភាពនៃទស្សនៈមូលធនសង្គមក៏ពិតមែន ប៉ុន្តែមានអ្នកឈានមុខជាច្រើននាក់ទៀត ដូចជា Lyda Judson Hanifan (1920), Jane Jacobs (1961), Pierre Bourdieu and Jean-Claude Passeron (1970) និង Glenn Loury (1977) ដែលបានយកទស្សនៈនេះមកបញ្ចូលក្នុងមុខវិជ្ជាវិទ្យាសាស្ត្រសង្គមតាំងពីមុននោះម្លេះ (cited in Sen 2010)។ Putnam បានកំណត់និយមន័យមូលធនសង្គមជា "លក្ខណៈនៃរចនាសម្ព័ន្ធសង្គម ដូចជា បណ្តាញ បទដ្ឋាន និងទំនុកចិត្តជាដើម ដែលផ្តល់ភាពងាយស្រួលដល់ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការដើម្បីផលចំណេញទៅវិញទៅមក" (Putnam 1993: 36) ហើយស្នាដៃរបស់គាត់ បានជួយបំផុសឲ្យមានការសរសេរឯកសារជាច្រើនអំពីទស្សនៈនេះ (Maloney *et al.* 2000; Lowndes & Wilson 2001; Wallis 2002)។

Putnam (1993) បានលើកថា ប្រពៃណីអំពីតួនាទីពលរដ្ឋនៅក្នុងសហគមន៍ មានឫសគល់នៅក្នុងប្រវត្តិសាស្ត្រ និងវប្បធម៌។ អ្នកនិពន្ធផ្សេងទៀត ក៏បានសិក្សាពីឥទ្ធិពលនៃមូលធនសង្គម ទៅលើការឆ្លើយតប និងប្រសិទ្ធភាពនៃបណ្តាស្ថាប័ននៅមូលដ្ឋាន (Newton 2001) ភាពជាសមាជិកនៃសមាគម និងអាកប្បកិរិយា និងសីលធម៌ជាពលរដ្ឋ (Wollenbxk & Selle 2003) ឥទ្ធិពលនៃបទពិសោធន៍ចងជាសមាគម (Hooghe 2003; Molenaers 2003; Stolle 2003; Veenstra 2003) និងឥទ្ធិពលនៃដង់ស៊ីតេការចូលជាសមាគម (de Hart & Dekker 2003)។

ធនាគារពិភពលោក មើលឃើញថា មូលធនសង្គមជាកត្តាដ៏សំខាន់មួយ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចរបស់សង្គម៖ "មូលធនសង្គមនៃសង្គមមួយ រួមមាន ស្ថាប័ននានា ទំនាក់ទំនង អាកប្បកិរិយា និងតម្លៃសីលធម៌ដែលគ្រប់គ្រងអន្តរកម្មរវាងប្រជាជន ហើយរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម" (Krishnamurthy 1999)។ មូលធនសង្គមវាផ្សារភ្ជាប់ខ្លួននៅក្នុងរចនាសម្ព័ន្ធស្ថាប័ន សង្គម និងវប្បធម៌របស់សង្គមមួយ។

[១] អត្ថបទនេះរៀបរៀងឡើងដោយលោក សែន វិចិត្រ ជាអ្នកស្រាវជ្រាវ និង កញ្ញា ហៀង ធីរ៉ាភមរី ជាជំនួយការកម្មវិធី ក្នុងកម្មវិធីអភិវឌ្ឍន៍សង្គមនៃវិទ្យាស្ថាន CDRI ។ អត្ថបទនេះសង្ខេបពីលទ្ធផលសំខាន់ៗបានមកពីអង្កេតលើស្ថានភាពមូលធនសង្គមនៅកម្ពុជា ដែលទទួលបានហិរញ្ញប្បទានពីមជ្ឈមណ្ឌលសម្រាប់ការសិក្សាមូលធនសង្គម នៃវិទ្យាស្ថានដើម្បីការអភិវឌ្ឍចំណេះដឹងសង្គម នៃសាកលវិទ្យាល័យ Senshu នៅប្រទេសជប៉ុន។ អង្កេតបានធ្វើឡើងពីខែកញ្ញា ២០១១ ដល់ មករា ២០១២។

រូបភាព ១៖ មូលធនសង្គមជាភាពផ្សារភ្ជាប់ ស្ពានចម្លង និងភាពតភ្ជាប់ចុះឡើង




*ប្រភព៖ Pellini & Ayres, (2005: 8)*

មូលធនសង្គមមានបីផ្នែក៖ ភាពផ្សារភ្ជាប់ ស្ពានចម្លង និងភាពតភ្ជាប់ទំនាក់ទំនងចុះឡើង។ ផ្នែកទី១ (ចំណងតភ្ជាប់ខ្លាំង) សំដៅដល់ "ការពង្រឹងចំណងទាក់ទងទៅវិញទៅមករវាងបុគ្គលនានាក្នុងសហគមន៍" រីឯផ្នែកទី២ (ចំណងតភ្ជាប់ខ្សោយ) សំដៅដល់ "ការចងជាសមាគមរបស់ក្រុមផ្សេងៗក្នុងសង្គម" (Halpern & Granovetter cited in Bouka 2008: 11)។ មូលធនសង្គមជាភាពផ្សារភ្ជាប់ វាមានលក្ខណៈផ្ទៃក្នុង និងមានប្រយោជន៍សម្រាប់ "ការកសាងអត្តសញ្ញាណសហគមន៍យ៉ាងរឹងមាំ" ហើយមូលធនសង្គមជាស្ពានចម្លង វាមានឥទ្ធិពលទៅខាងក្រៅ និងអាច "កសាងនូវបណ្តាញនៃបណ្តាញផ្សេងៗ" (Shopeju & Ojukwu 2008:6)។ រីឯផ្នែកទី៣ គឺភាពតភ្ជាប់ទំនាក់ទំនងចុះឡើង (ឬថាមពលចម្រុះ - synergy) សំដៅដល់ "ទំនាក់ទំនងរវាងស្រទាប់ផ្សេងៗនៃសង្គម ដូចជា ទំនាក់ទំនងរវាងរដ្ឋ និងសហគមន៍ ឬទំនាក់ទំនងរវាងសហគមន៍ ឬស្ថាប័ននានា ដែលមានធនធាន ឬអំណាចមិនស្មើគ្នា" (Bouka 2008: 13)។ ដោយសង្ខេប មូលធនសង្គមជាភាពផ្សារភ្ជាប់ និងស្ពានចម្លង សំដៅដល់ទំនាក់ទំនងតាមខ្សែផ្តេក រីឯមូលធនសង្គមជាភាពតភ្ជាប់ចុះឡើង វាសង្កត់ធ្ងន់លើទំនាក់ទំនងតាមខ្សែបញ្ឈរ (រូបភាព១)។

អង្កេតនេះបានធ្វើឡើងសំដៅកំណត់ពីការពិតជាក់ស្តែង និងសក្តានុពលនៅតាមមូលដ្ឋាន ដើម្បីបង្កើតយន្តការសង្គមឲ្យបានកាន់តែប្រសើរ តាមរយៈការពិនិត្យពីសង្គម សេដ្ឋកិច្ច និងអ្នកពាក់ព័ន្ធនានា នៅតាមតំបន់ជនបទ និងទីក្រុងនៅកម្ពុជា។ អង្កេតនេះផ្តោតលើប្រធានបទបួនសំខាន់ៗ គឺទំនុកចិត្តក្នុងសង្គម ការថែទាំនិងកែលំអជីវភាព ហានិភ័យនិងប្រព័ន្ធសុវត្ថិភាពសង្គម និងទម្លាប់/ពិធីក្នុងសង្គម។ អង្កេតបានធ្វើឡើង នៅភូមិជនបទមួយក្នុងខេត្តព្រៃវែង និងភូមិតំបន់ទីក្រុងមួយក្នុងខេត្តសៀមរាប ព្រមទាំង

បានជ្រើសរើសតាមលក្ខណៈជាប្រព័ន្ធនូវ សំណាកបានទាំងអស់ ៤០០គ្រួសារ (២០០គ្រួសារក្នុងមួយភូមិៗ)។

## លទ្ធផលសំខាន់ៗ

### *ទំនុកចិត្តក្នុងសង្គម*

ក្នុងសង្គមកម្ពុជា ទំនុកចិត្តតាំងពីដើមរៀងមកផ្ដោតលើការជាប់សាច់ឈាមជាគ្រួសារ និងស្ថិតក្នុងក្រុមតូចមួយនៃសាច់ញាតិជិតៗ (Grahn 2006)។ ភូមិកម្ពុជានានាតែងរៀបចំឡើងនៅជុំវិញសាច់ញាតិនេះ និងខ្វះខាតលក្ខណៈ "សមាគមផ្សេងៗនៃប្រជាជនដើមជាប្រពៃណី និងមានការរៀបចំល្អ ក្លឹបផ្សេងៗ បក្សពួក ឬក្រុមផ្សេងទៀតដែលត្រូវបានបង្កើតឡើងដោយឈរលើគោលការណ៍មិនមែនសាច់ញាតិ" (Ebihara 1968: 181)។ ដូចក្នុងសង្គមឯទៀតនៅអាស៊ីដែរ គ្រួសារជា "គំរូដើមនៃអង្គការសង្គមទាំងអស់"។ គំនិតចម្បង គឺមនុស្សម្នាក់មិនមែនជាបុគ្គលម្នាក់ទេ ប៉ុន្តែជាសមាជិកម្នាក់ក្នុងគ្រួសារ" (Hofstede cited in Pearson 2005: 3)។ គ្រួសារជាឯកតាមូលដ្ឋាននៃសង្គម ដែលជាប្រភព និងដែនកំណត់នៃទំនុកចិត្ត ពោលគឺ ទំនុកចិត្តមានកម្រិតព្រំដែនតែត្រឹមគ្រួសារតែប៉ុណ្ណោះ (UNICEF 1996)។ ទំនុកចិត្តមានកំណត់នេះ ជាលទ្ធផលនៃរដ្ឋបាលប្រមូលផ្ដុំ និងសេដ្ឋកិច្ចប្រើរូបិយវត្ថុ ដែលអាណានិគមបារាំងបានយកមកអនុវត្ត និងដែល "បានសង្កត់ធ្ងន់លើជំហរបុគ្គលនិយម និងបានកាត់បន្ថយស្មារតីសាមគ្គីភាពរវាងបុគ្គលនានា" (Pellini 2005: 8)។ ក្នុងសម័យមុនអាណានិគម ភូមិនៅកម្ពុជាមានលក្ខណៈជា សង្គមមួយដែលជីវិតរស់នៅពឹងផ្អែកលើ "និមិត្តរូបវប្បធម៌ សាសនា បែបបទសីលធម៌ និងសកម្មភាពសហគមន៍រួមគ្នា" (Gyallay- Pap cited in Pellini 2005: 8)។

បន្ទាប់ពីបានឯករាជ្យរហូតដល់ឆ្នាំ១៩៧០ កម្ពុជាមានស្មារតីសាមគ្គី និងស្មារតីសហគមន៍យ៉ាងរឹងមាំ៖ "ប្រជាជនមានធនធានគ្រប់គ្រាន់សម្រាប់ជីវភាពរស់នៅ ដូច្នេះអាចមានសប្បុរសធម៌ជាមួយសមាជិកគ្រួសារដែលមិនសូវធូរធារ និងប្រជាជនក្រីក្រផ្សេងទៀត" (UNICEF 1996: 41)។ បែបបទនៃសាមគ្គីភាព និងការជួយគ្នាទៅវិញទៅមកទាំងនេះ បានផ្លាស់ប្ដូរយ៉ាងលឿននៅពេលដែលកម្ពុជាធ្លាក់ចូលក្នុងសង្គ្រាមរ៉ាំរ៉ៃយូរឆ្នាំ ជាពិសេសរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ជម្លោះរ៉ាំរ៉ៃបានបង្កការខូចខាតមិនអាចស្ដាឡើងវិញបាន ដល់វប្បធម៌ដ៏យូរលង់របស់កម្ពុជា។ ទោះបីអ្នកស្រាវជ្រាវមួយចំនួន (Krishnamurthy 1999; Kim 2001; Ledgerwood & Vijghen 2002; Pellini 2005) យល់ថា មូលធនសង្គមនៅកម្ពុជាបានទទួលរងការខូចខាត ប៉ុន្តែមិនមែនបំផ្លាញខ្ទេចដោយសង្គ្រាមស៊ីវិល និងរបបខ្មែរក្រហមក្ដី ក៏លក្ខណៈនៃមូលធនសង្គម និងអន្តរកម្មក្នុងសង្គមនៅកម្ពុជានាបច្ចុប្បន្ន បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីផលប៉ះពាល់នៃសង្គ្រាម៖ "កង្វះទំនុកចិត្ត ការភ័យខ្លាច និងការបាក់បែកទំនាក់ទំនងក្នុងសង្គម នៅកម្ពុជាក្នុងពេលសព្វថ្ងៃ" (O'Leary & Meas 2001: 64)។

នៅកម្ពុជាក្រោយសម័យសង្គ្រាមនេះ ទំនុកចិត្តបានក្លាយជាកត្តាខ្វះខាតមួយ (UNICEF 1996)។ តម្លៃសីលធម៌សង្គមជាប្រពៃណី ដូចជា ស្មារតីរួបរួមគ្រួសារ និងគោរពសាសនា ត្រូវបានបំផ្លិចបំផ្លាញជាប្រព័ន្ធ (Pellini 2005: 9)។ សង្គមកម្ពុជានាពេលបច្ចុប្បន្នមានលក្ខណៈជាការបូកផ្សំនូវបុគ្គលជាច្រើនដែលយល់ថា "គ្មាននរណាម្នាក់អាចទុកចិត្តបានទាំងស្រុងនោះទេ។ ការយកចិត្តទុកដាក់ថែទាំដល់ខ្លួនឯង សំខាន់ខ្លាំងណាស់សម្រាប់ការរស់រានជីវិត" (UNICEF 1996: 41)។ កត្តាមួយដែលបង្កកង្វះធ្ងន់ធ្ងរនូវទំនុកចិត្តក្នុងសង្គម គឺ "ការរាំងស្ទះ និងការបំផ្លិចបំផ្លាញដល់ដំណើរការសហគមន៍តាមលំនាំចាស់ ដែលពឹងផ្អែកជាចម្បងលើបណ្ដាញសាច់ញាតិ" ( Pearson 2011: 38)។

លទ្ធផលអង្កេតបានបញ្ជាក់គាំទ្រដល់ការកត់សំគាល់ខាងលើដែលថា ប្រជាជនទាំងនៅតំបន់ជនបទ និងទីក្រុង មានទំនុកចិត្តកម្រិតទាបលើអ្នកដទៃ ដែលភាគច្រើនស្តែងចេញជាជំហរស្មុគ្រចិត្តកម្រិតទាប។ ក្នុងភូមិសិក្សានៅជនបទ ប្រជាជនបានបង្ហាញពីទំនុកចិត្តកម្រិតខ្ពស់តែចំពោះសមាជិកគ្រួសារ សាច់ញាតិ មិត្តភក្តិ និងអ្នកជិតខាងរបស់ខ្លួន។ ក្នុងភូមិនៅទីក្រុង មូលធនសង្គមជាភាពផ្សារភ្ជាប់ បានរួមចុះកាន់តែខ្លាំងថែមទៀត ដោយទំនុកចិត្តកម្រិតខ្ពស់ក្នុងសង្គម ឃើញមានបង្ហាញតែក្នុងរង្វង់សមាជិកគ្រួសារ និងសាច់ញាតិប៉ុណ្ណោះ។ រឿងនេះអាចមកពីសកម្មភាពសេដ្ឋកិច្ចមានសន្ទុះខ្លាំងនៅតំបន់ទីក្រុង។ អ្នកស្រាវជ្រាវខ្លះបានជជែកវែកញែកថា ការជ្រៀតចូលរបស់មូលធននិយមមកក្នុងប្រទេសកម្ពុជា ដោយសារការធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចនៅដើមទសវត្សរ៍១៩៩០ បាននាំឲ្យមានការថយចុះទំនុកចិត្ត សាមគ្គីភាពក្នុងសង្គម និងការជួយគ្នាទៅវិញទៅមក (UNICEF 1996; Krishnamurthy 1999; Hughes 2001; Ovesen *et al.* 1996)។

ទំនុកចិត្តក្នុងសង្គមកម្រិតទាបនៅកម្ពុជា អាចជាប់ទាក់ទងនឹង "កត្តាខាងអារម្មណ៍ ការយល់ដឹង និងប្រវត្តិសាស្ត្រ" ច្រើនបែបយ៉ាង (Pearson 2011: 37)។ Meas Nee (cited in Pearson 2011: 38) បានសង្ខេបគំនិតនេះយ៉ាងប្រសើរ ដោយកត់សំគាល់ថា "កេរ្តិ៍តំណែលពីអតីតកាល កម្រិតអំពើហិង្សានិងភាពនិរទោសពេលបច្ចុប្បន្ន របៀបដឹកនាំផ្ដាច់ការ និងការមិនទុកចិត្តគ្នាដ៏ជ្រាលជ្រៅ និងឥតស្រាកស្រាន្ត រវាងគណបក្សនយោបាយផ្សេងៗនៅកម្ពុជា នឹងអ្នកដឹកនាំនានា មិនបានជួយអ្វីដល់ប្រជាជនទូទៅ ក្នុងការបំបាត់កង្វះទំនុកចិត្តរបស់ខ្លួន ចំពោះអ្នកដឹកនាំ ឬចំពោះប្រជាជនផងគ្នានោះទេ"។ ដូច្នេះ លក្ខណៈមានឋានានុក្រមនៃសង្គម ដែលមានការតភ្ជាប់ទំនាក់ទំនងតាមខ្សែបញ្ឈរធូររលុង និងមូលធនសង្គមជាភាពផ្សារភ្ជាប់ដ៏តូចចង្អៀតបានត្រឹមតែបណ្ដាញដ៏ជិតស្និទ្ធបំផុតនោះ គឺត្រូវតែយកមកគិតគូរនៅពេលផ្ដួចផ្ដើមធ្វើការអភិវឌ្ឍប្រកបដោយសមធម៌ និងលក្ខណៈប្រជាធិបតេយ្យ (Pellini 2005)។

### *ការថែទាំ និងកែលំអជីវភាព*

សង្គមមួយដែលមានមូលធនសង្គមកម្រិតខ្ពស់ តែងមានប្រព័ន្ធទ្រទ្រង់យ៉ាងរឹងមាំ នោះគឺការទ្រទ្រង់ដែលប្រជាជនទទួលបាននៅពេលប្រឈមមុខនឹងការលំបាក។ លទ្ធផលអង្កេតបង្ហាញថា ប្រព័ន្ធទ្រទ្រង់សង្គមនៅកម្ពុជាភាគច្រើន មានលក្ខណៈ

ក្រៅផ្លូវការ។ នៅពេលត្រូវប្រឈមនឹងបញ្ហាប្រចាំថ្ងៃ ប្រជាជនតែងងាកទៅរកបណ្តាញផ្សារភ្ជាប់របស់ខ្លួនដើម្បីទទួលបានជំនួយទ្រទ្រង់ ជាពិសេសសមាជិកគ្រួសារ និងសាច់ញាតិ ក៏ដូចជាអ្នកចងការប្រាក់ក្រៅផ្លូវការនៅមូលដ្ឋាន និងស្ថាប័នមីក្រូហិរញ្ញវត្ថុដែលកាន់តែមានតួនាទីសំខាន់ឡើង។ នៅតាមតំបន់ជនបទ អ្នកចងការប្រាក់ហាក់ដូចជាសកម្មជាងក្នុងការផ្តល់ប្រាក់កម្ចីនៅពេលប្រជាជនជួបការលំបាកក្នុងជីវភាពប្រចាំថ្ងៃ។ ដោយសារតាមធម្មតា អ្នកចងការប្រាក់ក្រៅផ្លូវការតែងយកការប្រាក់ខ្ពស់ណាស់ ដូច្នេះប្រព័ន្ធទ្រទ្រង់នេះ បានក្លាយជាបន្ទុកមួយសម្រាប់ប្រជាជនមូលដ្ឋាន ហើយមិនមានប្រព័ន្ធទ្រទ្រង់សង្គមជាផ្លូវការសម្រាប់ជួយទេនៅពេលពួកគាត់ជួបការលំបាក។

ដោយសារកង្វះស្ថាប័នទ្រទ្រង់សង្គម និងដោយយល់ឃើញថាបណ្តាញជិតស្និទ្ធរបស់គាត់ក៏ជួបការលំបាកដូចគ្នា ប្រជាជនភាគច្រើនទាំងនៅតំបន់ជនបទ និងទីក្រុងជឿថា គាត់ត្រូវតែពឹងផ្អែកលើខ្លួនឯងក្នុងការដោះស្រាយជីវភាពរស់នៅ។

ព័ត៌មានដើរតួនាទីសំខាន់បំផុតសម្រាប់ឲ្យ ប្រជាជនទទួលបានឱកាសល្អដែលអាចជួយលើកកម្ពស់ជីវភាពរស់នៅ។ ប៉ុន្តែនៅកម្ពុជា ការផ្លាស់ប្តូរព័ត៌មាន ជាពិសេសនៅតំបន់ជនបទច្រើនតែ "កើតមានក្នុងបណ្តាញសង្គមដែលភាគច្រើនកើតមានឡើងដោយខ្លួនឯង មានលក្ខណៈក្រៅផ្លូវការ និងមិនទៀងទាត់" (Krishnamurthy 1999: 3)។ ភស្តុតាងបានមកពីអង្កេតទាំងនៅតំបន់ជនបទ និងទីក្រុង បានបង្ហាញថា ប្រភពព័ត៌មានចម្បងរបស់ប្រជាជន គឺមាន សមាជិកគ្រួសារ សាច់ញាតិ មិត្តភក្តិ និងអ្នកជិតខាង។ ទោះបីអាជ្ញាធរមូលដ្ឋាន និងប្រព័ន្ធផ្សព្វផ្សាយហាក់មានតួនាទីកាន់តែច្រើនឡើងក្តី ក៏ពួកគេហាក់ដូចធ្វើការផ្សព្វផ្សាយតែព័ត៌មានប្រភេទខ្លះៗប៉ុណ្ណោះ។

## *ហានិភ័យ និងសុវត្ថិភាពសង្គម*

លក្ខណៈសំគាល់មួយនៃសង្គមកម្ពុជា គឺបែបបទជាក្រឹត្យក្រមរឹងប៉ឹងដែលសាច់ញាតិត្រូវជួយគ្នាទៅវិញទៅមក នៅពេលជួបការលំបាក ហើយ "ក្រឹត្យក្រមនេះជួយបង្កើនទំនុកចិត្ត និងភាពអាចពឹងផ្អែកលើគ្នាបានក្នុងរង្វង់សាច់ញាតិ" (Krishnamurthy 1999: 61)។ សមាជិកគ្រួសារ និងសាច់ញាតិ ដើរតួនាទីជាបណ្តាញសុវត្ថិភាពក្រៅផ្លូវការដ៏រឹងមាំ ដូចអាចមើលឃើញក្នុងលទ្ធផលអង្កេតដែល ប្រជាជនភាគច្រើននៅតែចាត់ទុកគ្រួសារ និងសាច់ញាតិជាប្រព័ន្ធទ្រទ្រង់ក្រៅផ្លូវការដ៏សំខាន់ ទោះបីគំនិតនេះហាក់ដូចកំពុងផ្លាស់ប្តូរក្តី។ អ្នកឆ្លើយសម្ភាសន៍ជាច្រើននាក់នៅតំបន់ជនបទលើកឡើងថា គាត់អាចពឹងផ្អែកលើសមាជិកគ្រួសារ សាច់ញាតិ មិត្តភក្តិ និងអ្នកជិតខាងបាន នៅពេលជួបការលំបាក ឬហានិភ័យ។ នៅតំបន់ទីក្រុង បណ្តាញសុវត្ថិភាពសង្គមក្រៅផ្លូវការនៅតែរឹងមាំខ្លាំង ទោះបីវាហាក់ដូចបានរួមចុះមកត្រឹមសមាជិកគ្រួសារ និងសាច់ញាតិក្តី។

នៅកម្ពុជា បណ្តាញក្រៅផ្លូវការដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញចន្លោះខ្វះខាតដែលបណ្តាស្ថានប័ន និងទីភ្នាក់ងារផ្លូវការនានា មិនបានគ្របដណ្តប់ ជាពិសេសនៅតំបន់ជនបទ (Krishnamurthy 1999)។ "បណ្តាញក្រៅផ្លូវការបានរីកលូតលាស់ដោយសារទំនុកចិត្ត និងភាពអាចពឹងផ្អែកលើគ្នាបាន ដែលតែងកើតមានជាធម្មតាក្នុងចំណោមសាច់ញាតិ អ្នកជិតខាង និងមិត្តភក្តិ។ ទំនុកចិត្ត និងភាពអាចពឹងផ្អែកលើគ្នាបាននេះ បានផ្តល់បណ្តាញសុវត្ថិភាពដ៏សំខាន់បំផុតមួយដល់អ្នកភូមិ នៅពេលមានបញ្ហាកើតឡើង" (ibid: 63)។ នៅកម្ពុជា បណ្តាញក្រៅផ្លូវការដើរតួនាទីជាប្រព័ន្ធទ្រទ្រង់សង្គមដ៏រឹងមាំ ដោយសារពុំមានប្រព័ន្ធទ្រទ្រង់សង្គមផ្លូវការអ្វីច្បាស់លាស់។ បណ្តាញក្រៅផ្លូវការទាំងនេះផ្តល់ឲ្យបុគ្គលនានានូវ យន្តការជួយទ្រទ្រង់ដ៏មានតម្លៃនៅក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គមរបស់ពួកគេ (ibid)។

នៅប្រទេសកម្ពុជា ក្រោយពេលបញ្ចប់សង្គ្រាម បណ្តាញក្រៅផ្លូវការ និងបែបបទជួយគ្នាទៅវិញទៅមក ទំនងទទួលរងឥទ្ធិពលពីកម្លាំងទីផ្សារ និងហាក់បានផ្លាស់ប្តូរទៅកាន់ពលកម្មយកប្រាក់កម្រៃ និងទម្រង់នៃការដោះដូរផ្អែកលើទីផ្សារ (Kim 2001; Fitzgerald *et al.* 2007)។ កម្លាំងទីផ្សារ និងសេដ្ឋកិច្ចប្រើប្រាក់កាស បានធ្វើឲ្យបណ្តាញសុវត្ថិភាពក្រៅផ្លូវការផ្អែកលើការជួយគ្នាទៅវិញទៅមកត្រូវចុះខ្សោយជាបណ្តើរៗ ហើយជំរុញឲ្យប្រជាជនដាក់តម្រូវការ និងបញ្ហាផ្ទាល់ខ្លួនជារឿងសំខាន់ទី១ នៅក្នុងបរិយាកាសមានការប្រកួតប្រជែងខ្លាំងនេះ (Krishnamurthy 1999)។ នៅកម្ពុជាសម័យនេះ ប្រជាជនបានក្លាយជា "អាត្មានិយម លោភលន់ និងត្រៀមជួយតែចំពោះគ្រួសារនៅជិតខ្លួនគាត់ប៉ុណ្ណោះ។ ពួកគាត់មិនសូវមានឆន្ទៈចូលរួមក្នុង សកម្មភាពរួមដែលធ្វើឡើងសម្រាប់ជាប្រយោជន៍ដល់សហគមន៍ទាំងមូលនោះទេ" (UNICEF 1996: 41)។ នេះជានិន្នាការគួរឲ្យបារម្ភ ក្នុងស្ថានភាពបច្ចុប្បន្ននៅប្រទេសកម្ពុជា ដែលពុំទាន់មានប្រព័ន្ធទ្រទ្រង់សង្គមផ្លូវការ ហើយយុទ្ធសាស្ត្រការការពារសង្គមជាផ្លូវការ ក៏ទើបចាប់ផ្តើមកសាងឡើង។

## *ទម្លាប់/ពិធីក្នុងសង្គម*

ក្រៅពីគ្រួសារដែលជាឯកតាសង្គមជាមូលដ្ឋាន និងដែលដើរតួនាទីជាប្រព័ន្ធទ្រទ្រង់សង្គមក្រៅផ្លូវការជាមូលដ្ឋាន នៅកម្ពុជា បុណ្យទានរបស់សហគមន៍និងសម្រាប់ទូទាំងភូមិ ក៏ផ្តល់ជាវេទិកាមួយសម្រាប់ឲ្យប្រជាជនក្នុងសហគមន៍ ធ្វើអន្តរកម្មចុះឡើង ព្រមទាំងកសាងនិងពង្រឹងបណ្តាញរបស់ពួកគាត់។ Krishnamurthy (1993: 3) បានសង្ខេបថា "បុណ្យទានក្នុងសហគមន៍អាចបង្កើនស្មារតីសាមគ្គីភាព និងដើរតួជាស៊ីម៉ងត៍ផ្សារភ្ជាប់ប្រជាជនជាមួយគ្នា។ ព្រឹត្តិការណ៍ទាំងនោះបង្កើតបានជាសំណាញ់នៃស្មារតីសមូហភាព ឆ្លងតាមបទពិសោធន៍រួមគ្នា។ ព្រឹត្តិការណ៍ក្នុងសហគមន៍ អាចជួយដាស់ស្មារតីប្រជាពលរដ្ឋល្អ និងលើកកម្ពស់ជំហរគិតគូរដល់សុខទុក្ខរបស់អ្នកដទៃ"។

លទ្ធផលអង្កេតបានបង្ហាញថា ការចូលរួមនៅក្នុងព្រឹត្តិការណ៍សហគមន៍នៅមានសន្ទុះខ្លាំង ជាពិសេសនៅតាមតំបន់ជនបទ ហើយគេក៏អាចពិនិត្យឃើញតាមរយៈសមាសភាពអ្នកចូលរួមនៅក្នុងពិធីផ្សេងៗដូចជា មង្គលការ និងបុណ្យសព ជាដើម។ សមាជិកគ្រួសារ សាច់ញាតិ មិត្តភក្តិ និងអ្នកជិតខាង គឺជាអ្នកចូលរួមនៅក្នុងពិធីប្រពៃណីទាំងនោះ ទាំងនៅតាមតំបន់ជនបទ និងនៅតាមទីក្រុង។ ប៉ុន្តែ ទោះបីជាព្រឹត្តិការណ៍ប្រភេទនេះរួមចំណែកលើក

កម្ពស់សាមគ្គីភាពក្នុងសហគមន៍ក្តី ក៏ការចូលរួមក្នុងពិធីទាំងនេះ អាចមានលក្ខណៈទៅវិញទៅមក គឺមិនមែនសុទ្ធតែបង្ហាញពីទំនាក់ទំនងក្នុងសង្គមនោះទេ។

នៅតាមភូមិនានានៅតំបន់ជនបទ ការចូលរួមក្នុងពិធីប្រពៃណីផ្សេងៗនៅមានច្រើនណាស់។ ពិធីប្រពៃណីរបស់សហគមន៍មានសារៈសំខាន់ក្នុងការ "លើកកម្ពស់អត្តសញ្ញាណរបស់សហគមន៍ និងសាមគ្គីភាព" (Krishnamurthy 1999: 63)។ ផ្ទុយទៅវិញ ព្រឹត្តិការណ៍នៅក្នុងសហគមន៍បែបនេះ ហាក់ដូចជាពុំឃើញមានទេក្នុងភូមិនៅតាមទីក្រុង ហើយនេះបានប៉ះពាល់ដល់សាមគ្គីភាព និងស្មារតីសហគមន៍ដែលត្រូវរងឥទ្ធិពលថែមទៀត ពីសន្ទុះនៃកម្លាំងទីផ្សារ និងការប្រកួតប្រជែងនៅតំបន់ទីក្រុង។

នាបច្ចុប្បន្ន ទាំងតាមមតិរបស់របស់ស្ត្រីខ្លួនឯង និងរបស់បុរស គឺហាក់ដូចមានការផ្លាស់ប្តូរតួនាទីរបស់ស្ត្រី ជាពិសេសនៅតំបន់ទីក្រុង។ សង្គមកម្ពុជា បានក្លាយជារចនាសម្ព័ន្ធមួយដែលលើកបុរសជាធំ ហើយលក្ខណៈនេះអាចមើលឃើញច្បាស់តាមការគួបផ្សំគ្នាជាធម្មតា រវាងការងាររបស់បុរស និងការងាររបស់ស្ត្រី ដោយបុរសជាប្រពៃណី តែងមានតួនាទីចម្បងគេនៅក្នុងគ្រួសារ និងទទួលបន្ទុកលើការងារធ្ងន់ៗ ឬការងារមានគ្រោះថ្នាក់ច្រើន ហើយស្ត្រីជាទូទៅទទួលបន្ទុកលើការងារនៅក្នុងផ្ទះ។ ភស្តុតាងបានពីអង្កេតនៅតាមតំបន់ជនបទ ហាក់ដូចជាបានបញ្ជាក់គាំទ្រដល់ចំណុចនេះ ទោះបីជាប្រជាជនមួយចំនួន ជាពិសេសស្ត្រី បានផ្លាស់ប្តូរគំនិតខ្លះហើយ ដោយបានគិតថា ស្ត្រីគួរទទួលបន្ទុកលើការងារដែលជាការងាររ៉ាប់រងដោយបុរស និងគួរបង្កើនការចូលរួមក្នុងក្រុមសកម្មភាពសហគមន៍មូលដ្ឋាន។ ការផ្លាស់ប្តូរកាន់តែឃើញមានច្បាស់ឡើងថែមទៀតនៅតាមតំបន់ទីក្រុង។ បុរស និងស្ត្រីក្នុងចំនួនស្ទើរស្មើគ្នាយល់ឃើញថា ស្ត្រីគួរបំពេញការងារដូចគ្នានឹងបុរសដែរ ដូចជា ការគ្រប់គ្រងអាជីវកម្មរបស់ខ្លួនផ្ទាល់ និងការចូលរួមនៅក្នុងសកម្មភាពសេវាកម្ម។ គំនិតនេះអាចបណ្តាលមកពីនៅតាមតំបន់ទីក្រុង តែងមានសកម្មភាពសេដ្ឋកិច្ចមមាញឹក និងឱកាសច្រើន។

សាសនាដើរតួនាទីសំខាន់បំផុត ក្នុងការកំណត់បែបបទក្រឹត្យក្រមនៃការជួយគ្នាទៅវិញទៅមកក្នុងសង្គម។ ក្នុងសង្គមកម្ពុជាក៏ដូច្នោះដែរ ដោយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋបានទូន្មានឲ្យលើកកម្ពស់ ការចូលរួមក្នុងសកម្មភាពសហគមន៍ (Kim 2001; Pellini 2005)។ អ្នកឆ្លើយសម្ភាសន៍ក្នុងអង្កេតទាំងអស់ ទាំងនៅតំបន់ជនបទ និងទីក្រុង សុទ្ធតែជាអ្នកកាន់ពុទ្ធសាសនា។ ព្រះវិហារពុទ្ធសាសនា (ឬវត្ត) គឺជា មជ្ឈមណ្ឌលនៃជីវិតសហគមន៍នៅប្រទេសកម្ពុជា។ ទោះយ៉ាងណាក្តី សព្វថ្ងៃនេះសាសនាមិនដើរតួនាទីសំខាន់ក្នុងជីវភាពប្រចាំថ្ងៃ ដូចកាលពីមុនទេ។ ទាំងនៅតំបន់ជនបទ និងទីក្រុង មានប្រជាជនតិចនាក់ណាស់ដែលចាត់ទុកវត្ត ជាកន្លែងដែលពួកគាត់អាចពឹងអាស្រ័យ និងទទួលបានការទ្រទ្រង់ នៅពេលគាត់ជួបនឹងការលំបាក។ រឿងនេះអាចជាប់ទាក់ទងនឹងការចោទប្រកាន់នាពេលថ្មីៗដែលថា វត្តមិនមែនជាកន្លែងអព្យាក្រិតទេ ហើយអ្នកដឹកនាំសាសនាមានជាប់ខ្សែរយៈជាមួយ គណបក្សនយោបាយ (Heng 2008; Thon *et al.* 2009)។ សម្រាប់ប្រជាជនជាច្រើន បញ្ហានេះ បានបំផ្លាញតួនាទីមូលដ្ឋានរបស់សាសនានៅក្នុងជីវិតរស់នៅរបស់ពួកគាត់ ហើយពុទ្ធសាសនាលែងមានន័យអ្វីច្រើនសម្រាប់ពួកគាត់ទៀតហើយ។

## សន្និដ្ឋាន

លទ្ធផលអង្កេតបានផ្តល់ការយល់ដឹងយ៉ាងល្អ អំពីលក្ខណៈនៃមូលធនសង្គម ជាភាពផ្សារភ្ជាប់ ស្ពានចម្លង និងភាពតភ្ជាប់ចុះឡើង នៅតាមតំបន់ជនបទ និងទីក្រុង នៅក្នុងប្រទេសកម្ពុជា។ មូលធនសង្គមជាភាពផ្សារភ្ជាប់នៅរឹងមាំនៅឡើយ ទោះបីជានៅតាមតំបន់ទីក្រុង វាហាក់ដូចជាបានរួមចុះបន្តិចក្តី។ បែបបទក្រឹត្យក្រមជាប្រពៃណីដែលលើកស្ទួយដល់គ្រួសារជា ស្ថាប័នសង្គមដ៏ចម្បង សម្រាប់ដោះស្រាយតម្រូវការគ្រប់ប្រភេទរបស់សមាជិក វានៅគង់វង្សល្អ និងមានអនុវត្តយ៉ាងទូលំទូលាយទាំងនៅតំបន់ជនបទ និងនៅទីក្រុង។ សាច់ញាតិជិតៗ (ហើយនៅតាមតំបន់ជនបទ មានមិត្តភក្តិ និងអ្នកជិតខាង ផងដែរ) បង្កើតបានជាប្រព័ន្ធទ្រទ្រង់សង្គមក្រៅផ្លូវការយ៉ាងសំខាន់ ហើយពួកគាត់គឺជាអ្នកដែលអាចគេធ្វើសេចក្តីទុកចិត្តបាន។

មូលធនសង្គមជាស្ពានចម្លង ហាក់ដូចនៅរឹងមាំនៅឡើយក្នុងសហគមន៍នៅជនបទ ដែលនៅទីនោះ ប្រជាជនក្នុងមូលដ្ឋានតែងរៀបចំ និងទៅចូលរួមក្នុងពិធីជាប្រពៃណីផ្សេងៗ។ ប៉ុន្តែមូលធនសង្គមប្រភេទនេះហាក់ដូចបានរួមចុះនៅតំបន់ទីក្រុង ដោយសារពុំមានពិធីជាប្រពៃណីសម្រាប់ទូទាំងសហគមន៍ ថ្វីបើការចូលរួមក្នុងពិធីជាប្រពៃណីដូចជា មង្គលការ ឬបុណ្យសពជាដើម នៅតែមានកម្រិតខ្ពស់ក្តី។ ការផ្លាស់ប្តូរអាកប្បកិរិយារបស់ប្រជាជនចំពោះវត្តអារាមដែលជាមជ្ឈមណ្ឌលនៃជីវិតក្នុងសហគមន៍ ក៏បានប៉ះពាល់ដល់ចរិត និងកម្រិតនៃមូលធនសង្គមជាស្ពានចម្លងដែរ ជាពិសេសនៅតំបន់ទីក្រុង។

"សង្គមកម្ពុជាបច្ចុប្បន្ន អាចសំគាល់បានតាមការតភ្ជាប់ទំនាក់ទំនងតាមខ្សែបញ្ឈរធូររលុង រវាងក្រុមខុសៗគ្នា និងការតភ្ជាប់ទំនាក់ទំនងយ៉ាងរឹងមាំ រវាងសមាជិកនានាក្នុងស្រទាប់សង្គមតែមួយ" (Pellini 2005: 8)។ ហើយលទ្ធផលអង្កេតបានបញ្ជាក់គាំទ្រជាខ្លាំងលើចំណុចនេះ។ ទាំងនៅតំបន់ជនបទ និងទីក្រុង ប្រជាជនបានបង្ហាញទំនុកចិត្តកម្រិតទាបចំពោះស្ថាប័នរដ្ឋ និងអ្នកកាន់ក្តាប់អំណាចរដ្ឋ ដូចជា ក្រុមប្រឹក្សាឃុំសង្កាត់ជាដើម។ ម្យ៉ាងទៀត តាមសំដីរបស់អ្នកឆ្លើយសម្ភាសន៍ក្នុងអង្កេតជាពិសេសតំបន់ទីក្រុង គឺមានការមិនទុកចិត្តកម្រិតខ្ពស់ចំពោះគណបក្សនយោបាយ និងអ្នកនយោបាយនានា។

ជាទូទៅ មូលធនសង្គមជាភាពតភ្ជាប់ទំនាក់ទំនងចុះឡើង ទាំងនៅសហគមន៍តំបន់ជនបទនិងទីក្រុងវាមានកម្រិតទាបជាពិសេសនៅតំបន់ជនបទ ដែលតាំងពីដើមរៀងមក តែងនៅដាច់ឆ្ងាយពីអាជ្ញាធរថ្នាក់មជ្ឈឹមដែលនៅឯទីក្រុង (Pellini 2005) ហើយ "ប្រជាជននៅតំបន់ជនបទ ស្ទើរតែគ្មានការតភ្ជាប់ទំនាក់ទំនងអ្វីសោះជាមួយស្ថាប័នរដ្ឋ" (Grahn 2006: 31)។ នៅកម្ពុជា មូលធនសង្គមជាភាពតភ្ជាប់ដែលមានកម្រិតទាប ក៏អាចបណ្តាលពីរចនាសម្ព័ន្ធមានឋានានុក្រមដែលបានចាក់ឫសយ៉ាងជ្រៅ នៅក្នុងគ្រប់ទម្រង់នៃអន្តរកម្ម និងទំនាក់ទំនង នៅក្នុងវប្បធម៌កម្ពុជា។

ហើយរបៀបរបបដឹកនាំ និងវប្បធម៌អំពើហិង្សា និងនិរទោស នៅកម្ពុជានាបច្ចុប្បន្ន បានធ្វើឲ្យប្រជាជនកាន់តែឃ្លាតឆ្ងាយពីរដ្ឋថែមទៀត (Meas cited in Pearson 2011)។

## ឯកសារយោង


Bouka, Y. (2008), *Is social capital the key to peacebuilding?* Paper presented at the Annual meeting of the International Studies Association's 49th Annual Convention, Bridging Multiple Divides. Hilton San Francisco, California, www.allacademic.com/meta/p252132_index.html (accessed 31 October 2008)

Coleman, J.S. (1988), "Social capital in the creation of human capital", *American Journal of Sociology,* 94, 95-120

de Hart, J. & P. Dekker (2003), "A tale of two cities: Local patterns of social capital", in M.Hooghe & D. Stolle (eds.), *Generating Social Capital: Civil Society and Institutions in Comparative Perspective* (New York: Palgrave) 153-170

Ebihara, M.M. (1968), *Svay, a Khmer Village in Cambodia*, unpublished PhD dissertation, Faculty of Philosophy, Columbia University

Fitzgerald, I., So S., Chan S., Kem S. & S. Tout (2007), *Moving Out of Poverty? Trends in Community Well-being and Household Mobility in Nine Cambodian Village,* CDRI Working Paper (Phnom Penh: CDRI)

Grahn, H. (2006), *In the search of trust: A study on the origin of social capital in Cambodia from an institutional perspective*, Department of Political Science, LUND University

Heng, S. (2008), "The Scope and Limitations of Political Participation by Buddhist Monks", in A. Kent & D. Chandler (eds.), *People of Virtue: Reconfiguring Religion, Power and Moral Order in Cambodia Today* (Copenhagen: Nordic Institute of Asian Studies) 241-256

Hooghe, M. (2003), "Voluntary associations and democratic attitudes: Value congruence as a causal mechanism", in M. Hooghe & D. Stolle (eds.), *Generating Social Capital: Civil Society and Institutions in Comparative Perspective* (New York: Palgrave) 89-112

Hughes, C. (2001), *An Investigation of Conflict Management in Cambodian Villages: A Review of the Literature with Suggestions for Future Research* (Phnom Penh: Centre for Peace and Development, CDRI)

Kim S. (2001). *Reciprocity: Informal Patterns of Social Interactions in a Cambodian Village near Angkor Park*, MA thesis, Northern Illinois University, Dekalb, Illinois

Krishnamurthy, V. (1999), *The impact of armed conflict on social capital: A study of two villages in Cambodia* (Phnom Penh: Social Services of Cambodia)

Ledgerwood, J. & J. Vijghen. (2002), "Decision Making in Rural Khmer Villages", in J. Ledgerwood (ed.), *Cambodia Emerges from the Past: Eight Essays* (Dekalb, Illinois: Northern Illinois University)

Lowndes, V. & D. Wilson (2001), "Social Capital and Local Governance: Exploring the Institutional Design Variable", *Political Studies,* 49, 629-647

Maloney, W., G. Smith & G. Stoker (2000), "Social Capital and Urban Governance: Adding a More Contextualized 'Top-down' Perspective", *Political Studies,* 48, 802-820

Newton, K. (2001), "Trust, social capital, civil society, and democracy", *International Political Science Review,* 22(2), 201-214

O'Leary, M. & N. Meas (2001), *Learning for transformation: A study of the relationship between culture, values, experience and development practice in Cambodia* (Phnom Penh: Krom Akphiwat Phum)

Ovesen, J., I. Trankell & J. Ojendal (1996), *When Every Household is an Island: Social Organization and Power Structures in Rural Cambodia* (Stockholm: Department of Anthropology, Uppsala University)

Pearson, J. (2005), *The multi-cultural iceberg: Exploring international relationships in Cambodian development organizations*, INTRAC PraxiNote 8

Pearson, J. (2011), *Creative Capacity Development: Learning to Adapt in Development Practice.* (Sterling, VA: Kumarian Press)

Pellini, A. (2005), "Traditional Forms of Social Capital in Cambodia and their Linkage with Local Development Processes" *Cambodia Development Review,* 9(3), 8-11

Pellini, A. & D. Ayres (2005), *Social capital and village governance: Experiences with village networks*, GTZ (German Technical Cooperation Agency) discussion paper, www.worldbank.org (accessed 10 November 2008)

Putnam, R. (1993), *Making Democracy Work: Civic Traditions in Modern Italy* (Princeton, NJ: Princeton University Press)

Sen, V. (2010), *Trust and Conflict Transformation: An Analysis of the Baku Bae Peace Movement in Indonesia* (Saarbrücken, Germany: LAP LAMBERT Academic Publishing)

Shopeju, J. O. & C.C. Ojukwu (2008), *Exploring social capital as capacity for peace-building in Nigeria*, paper presented at the 1st Annual Conference of the Society for Peace Studies and Practice, www.spspng.org/papers.php (31 October 2008)

Thon V., Ou S., Eng N. & Ly T. (2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces,* CDRI Working Paper Series No. 42 (Phnom Penh: CDRI)

UNICEF (1996), *Towards a better future: An analysis of the situation of children and women in Cambodia* (Phnom Penh: UNICEF)

Wallis, J. (2002), "Social capital and local government capacity" *Australian Journal of Public Administration,* 61(3), 76-85

Wollebæk, D. & P. Selle (2003), "The importance of passive membership for social capital formation", in M. Hooghe & D. Stolle (eds.), *Generating Social Capital: Civil Society and Institutions in Comparative Perspective* (New York: Palgrave) 67-88